វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
ក្រសួងផែនការ
សាកល វិទ្យាល័យភូមិន្ទភ្នំពេញ
IDRC | CRDI
ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
ទីស្តីការគណៈរដ្ឋមន្ត្រី

សង្ខេបសម្រាប់ គោលនយោបាយ

ឆ្នាំ ២០១២ លេខ ០៣

# ចម្លើយតបរបស់រដ្ឋាភិបាលចំពោះវិបត្តិអតិផរណា និងវិបត្តិហិរញ្ញវត្ថុសាកល

*ហៃ សុវុទ្ធា*[១]

## សេចក្តីផ្តើម

កំណើនយ៉ាងខ្ពស់ ដែលកម្ពុជាសម្រេចបានក្នុងទសវត្សរ៍ចុងក្រោយនេះ បានពឹងផ្អែកជាខ្លាំងលើការនាំចេញទៅទីផ្សារសាកល ជាពិសេស ទីផ្សារសហរដ្ឋអាមេរិក និងអឺរ៉ុប វិនិយោគផ្ទាល់ពីបរទេស (FDI) និងជំនួយអភិវឌ្ឍន៍ផ្លូវការ ក្រោមរបបសេដ្ឋកិច្ចសេរីភាវូបនីយកម្មបើកទូលាយ។ ដូច្នេះ ទីផ្សាររបស់កម្ពុជាមិនងាយរួចផុតពីព្យុះសាកលទេ។ វិបត្តិសាកលទន្ទឹមគ្នាទាំងពីរ ជាការដាស់អារម្មណ៍ទាន់ពេលវេលាមួយ ដោយគូសបញ្ជាក់ពីបញ្ហាប្រឈមសំខាន់ៗ និងឱកាសសម្រាប់ស្ថិរភាពសេដ្ឋកិច្ច កំណើន និងវិបុលភាពនាពេលអនាគតរបស់កម្ពុជា។ អត្ថបទនេះ បូកសរុបពីគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចក្នុងស្រុក ក្នុងការកាត់បន្ថយអតិផរណាដ៏ខ្ពស់បំផុត និងកំណើនដ៏ទាបបំផុតដែលកម្ពុជាបានជួបប្រទះចាប់តាំងពីឆ្នាំ១៩៩៤ មក។ ផ្អែកលើបទពិសោធន៍រៀនសូត្របាន អត្ថបទនេះផ្តល់ជាគំនិតពី វិធីពង្រឹងប្រសិទ្ធភាពគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចមួយចំនួន។

## វិបត្តិអតិផរណា

កម្រិតថ្លៃខ្ពស់ ដោយសារកំណើនឥតរំពឹងទុកក្នុងសាកលលោកនូវតម្រូវការផលិតផល បានប៉ះពាល់ស្ទើរតែភ្លាមៗដល់ថ្លៃស្បៀងអាហារនៅកម្ពុជា ដែលធ្វើឲ្យអតិផរណាក្នុងស្រុកកើនឡើងយ៉ាងលឿន។ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (CPI) ប្រៀបធៀបឆ្នាំ (year-on-year CPI) ចាប់ផ្តើមកើនឡើងនៅខែមិថុនា ២០០៧ ដោយមានកំណើន ៧,៦% លើមធ្យមភាគខ្ពស់បំផុត ៥% សម្រាប់ទសវត្សរ៍ចុងក្រោយនេះ ដែលជម្រុញឡើងដោយកំណើនថ្លៃស្បៀងអាហារដល់ទៅ ៩,២%។ នៅខែមីនា ២០០៨ អតិផរណា CPI បានកើនដល់ ២៦,៦% ដោយសារកំណើន ១៧,១% ក្នុងថ្លៃអាហារ និង ៣,៥% ក្នុងថ្លៃដឹកជញ្ជូន ហើយបន្ទាប់មក កើនខ្ពស់បំផុតដល់ ៣៥,៤% នៅខែឧសភា ២០០៨ ដោយសារកំណើន ២៣,៤% ក្នុងថ្លៃអាហារ និង ៣,៤៦% ក្នុងថ្លៃដឹកជញ្ជូន។

មូលហេតុចម្បងនៃកំណើនថ្លៃអាហារ និងប្រេងឥន្ធនៈ គឺកំណើនថ្លៃទំនិញ និងប្រេងឥន្ធនៈយ៉ាងខ្លាំងក្នុងពិភពលោក។ អតិផរណា និងអតិផរណាស្បៀងអាហារនៅកម្ពុជា ដើរស្របគ្នាជាខ្លាំង ជាមួយនឹងនិន្នាការក្នុងប្រទេសដៃគូពាណិជ្ជកម្មនៅជិតខាងគឺ ថៃ និងវៀតណាម ហើយដើរទាន់គ្នាជាមួយនឹងថ្លៃអាហារក្នុងប្រទេសទាំងពីរក្នុងរយៈពេលពីរឬបីខែ ដោយសារពាណិជ្ជកម្មស្បៀងអាហារឆ្លងកាត់ព្រំដែនមានកម្រិតខ្ពស់ និងទីផ្សារផលិតផលមានលក្ខណៈ សមាហរណកម្មចូលគ្នាខ្លាំង។ ម្យ៉ាងទៀត អតិផរណាវាកាន់តែធ្ងន់ធ្ងរឡើង ដោយសារការប្រើប្រាស់ច្រើនហួសកម្រិត ដូចអាចមើលឃើញច្បាស់តាមគម្លាត ផសស (output-gap) ដែលបង្ហាញពីសញ្ញានានានៃសេដ្ឋកិច្ចរត់លឿនពេក និងត្រូវបានជម្រុញឡើងមួយកម្រិតទៀតដោយសារកត្តាមួយចំនួន គឺចំណាយឯកជន កំណើនពុះកញ្ជ្រោលខាងអចលនទ្រព្យ កំណើនល្បឿនចរាចររូបិយវត្ថុ និងកំណើនឥណទានយ៉ាងលឿន។

កំណើនអតិផរណា ជះឥទ្ធិពលធ្ងន់ធ្ងរដល់កិច្ចប្រឹងប្រែងអភិវឌ្ឍន៍ជាតិ ជាពិសេស ការកាត់បន្ថយភាពក្រីក្រ។ កំណើនថ្លៃអាហារ បានប៉ះពាល់ខ្លាំងជាងគេដល់ជនក្រីក្រ និងក្រុមងាយរងគ្រោះ ជាពិសេស អ្នកទិញអាហារ និងប្រជាជន ១,៧ លាននាក់ ដែលជាគ្រួសារមានអសន្តិសុខស្បៀងរស់នៅតាមតំបន់ទន្លេសាប និងតំបន់វាលទំនាប។ នៅកម្ពុជា ប្រជាជន ៤០% ដែលក្រីក្រជាងគេ ត្រូវចំណាយ ៧០% នៃចំណូលរបស់ខ្លួនទៅលើអាហារ (CSES 2004)។ ថ្លៃទំនិញខ្ពស់គួរតែបានផ្តល់ផលចំណេញទៅដល់ផលិតករជនបទ ប៉ុន្តែ Chan (2008) បានបង្ហាញថា មានកសិករតែ ២៥% ប៉ុណ្ណោះដែលទទួលបានផលចំណេញ ពីព្រោះមានកសិករត្រឹមតែ ៣៤% ដែលមានអតិរេកផលិតផលនៅឆ្នាំ២០០៨

[១] លោក ហៃ សុវុទ្ធា ជាអ្នកស្រាវជ្រាវ នៅអង្គភាពគោលនយោបាយសង្គម នៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ។

ហើយគ្រួសារជនបទ ២១% គ្មានដីផ្ទាល់ខ្លួនទេ និង ៤៥% មានដីតិចតួច (មានដីមួយហិកតា ឬតិចជាងនេះ)។

ដើម្បីដោះស្រាយផលប៉ះពាល់ភ្លាមៗនៃ អតិផរណាថ្លៃអាហារ មានការអនុវត្តវិធានការរដ្ឋបាលសំខាន់ៗមួយចំនួន រួមមាន ការលក់អង្ករ ៣០០តោន ថ្លៃ ១៨០០រៀល/គ.ក្រ ដែលទាបជាងថ្លៃទីផ្សារ (២៥០០រៀល/គ.ក្រ) ការផ្អាកការនាំចេញអង្ករបណ្ដោះអាសន្ន និងការផ្ដល់ឥណទាន ១២លានដុល្លារទៅឲ្យធនាគារអភិវឌ្ឍន៍ជនបទ។ វិធានការចម្បងៗ លើកំណើនថ្លៃប្រេងឥន្ធនៈ មានការកំណត់ថ្លៃគោលសម្រាប់គិតពន្ធ និងការរក្សាស្ថិរភាពថ្លៃអគ្គិសនី ដោយប្រើឧបត្ថម្ភធនពីរដ្ឋាភិបាល។

ម៉្យាងទៀត រដ្ឋាភិបាលបានប្រើវិធីមួយចំនួនអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចយ៉ាងលឿន ដែលសម្របសម្រួលឡើងដោយក្រុមត្រួតពិនិត្យថ្លៃ ដោយមានការគាំទ្រពីគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ គោលនយោបាយសារពើពន្ធដ៏ប្រយ័ត្នប្រយែង ព្រមជាមួយនឹងប្រាក់បញ្ញើដែលសន្សំបាន បានផ្ដល់លទ្ធភាពឲ្យមានការលើកលែងពន្ធនាំចូលលើ ប្រភេទផលិតផលដែលមានលក្ខណៈរសើប (sensitive-products) ការផ្ដល់ឧបត្ថម្ភធនផ្សេងៗ និងការគ្រប់គ្រងតឹងរឹងលើចំណាយសាធារណៈ។ ខាងផ្នែកគោលនយោបាយរូបិយវត្ថុវិញ កំណើនថ្លៃអាហារ និងប្រេងឥន្ធនៈនាំឲ្យមានតម្រូវការប្រាក់ដុល្លារខ្ពស់។ ប្រសិនបើគ្មានអន្តរាគមន៍ពីធនាគារជាតិនៃកម្ពុជា (NBC) ទាន់ពេលវេលាទេ សម្ពាធអតិផរណានឹងកាន់តែធ្ងន់ធ្ងរឡើង ដោយសារគំនួបនៃការធ្លាក់ថ្លៃប្រាក់រៀល និងផលឆ្លងកាត់ (pass-through effect)។ ទោះបីមានអន្តរាគមន៍រក្សាស្ថិរភាពអត្រាប្ដូរប្រាក់ក្ដី ក៏ផលឆ្លងកាត់នៅតែរាលដាល។ ម៉្យាងទៀត អន្តរាគមន៍ណាមួយដែលនាំឲ្យប្រាក់រៀលឡើងថ្លៃ ធៀបនឹងអត្រាប្ដូរប្រាក់ពីដំបូង នឹងប៉ះពាល់ដល់ភាពប្រកួតប្រជែងពាណិជ្ជកម្ម។ ដូច្នេះ ការធ្លាក់ថ្លៃប្រាក់រៀល និងផលឆ្លងកាត់ នាំឲ្យគោលនយោបាយរូបិយវត្ថុគ្មានប្រសិទ្ធភាព ក្នុងការទប់ទល់នឹងអតិផរណាកើតចេញពីប្រភពខាងក្រៅនេះ។

ធនាគារកណ្ដាល និងរដ្ឋាភិបាល មានលទ្ធភាពតិចតួចក្នុងការគ្រប់គ្រងអតិផរណាកើតចេញពីប្រភពខាងក្រៅ ដោយជាទូទៅ អាចគ្រាន់តែសម្រាលផលប៉ះពាល់អាក្រក់ខ្លះ និងទប់ស្កាត់ឥទ្ធិពលជុំទី២ តាមរយៈការគ្រប់គ្រងអត្រាប្ដូរប្រាក់។ ដោយឡែក គោលនយោបាយអត្រាប្ដូរប្រាក់ភាគច្រើនគ្មានប្រសិទ្ធភាពទេ ក្នុងការកាត់បន្ថយអតិផរណា ប៉ុន្តែកាតព្វកិច្ចទុនបម្រុង (reserve requirement) និងពិដានឥណទាន (credit ceiling) បានជួយញ៉ាំងឲ្យសេដ្ឋកិច្ចដែលរត់លឿនក្ដៅពេក វាថយល្បឿនត្រជាក់មកវិញបន្តិចតាមការទប់កំណើនឥណទាន។ កំណើនប្រាក់បញ្ញើរបស់រដ្ឋាភិបាលក្នុងអំឡុងពេលមានកំណើនសេដ្ឋកិច្ចខ្ពស់ បានអនុញ្ញាតឲ្យមានភាពបត់បែនខាងគោលនយោបាយសារពើពន្ធ ហើយគោលនយោបាយសារពើពន្ធបង្រួម មានប្រសិទ្ធភាពល្អក្នុងការគ្រប់គ្រងលើតម្រូវការសរុប។ ជារួម ការសម្របសម្រួល និងភាពបំពេញឲ្យគ្នារវាងគោលនយោបាយរូបិយវត្ថុ និងគោលនយោបាយសារពើពន្ធ គឺអនុវត្តបានល្អគួរកោតសរសើរ ហើយការចាត់វិធានការខាងរដ្ឋបាល ដើម្បីដោះស្រាយបញ្ហាផុសថ្មីនានា គឺធ្វើបានម៉ឺងម៉ាត់និងទាន់ពេលវេលា។

## បទពិសោធន៍កំណើនទាបបំផុត

ការផ្ទុះវិបត្តិសេដ្ឋកិច្ចសាកល ភ្លាមៗតាមក្រោយបន្តពីវិបត្តិថ្លៃអាហារ បានប៉ះទង្គិចប្រទេសកម្ពុជាធ្ងន់ធ្ងរ និងបង្អាក់ដំណើរ កំណើន មួយទសវត្សរ៍កន្លងមក និងការកាត់បន្ថយភាពក្រីក្រ។ កំណើនបន្តមានរហូតដល់ត្រីមាសទី៣ ឆ្នាំ២០០៨ ទើបធ្លាក់ចុះមកត្រឹម ០,១% នៅឆ្នាំ២០០៩ ដែលពន្យល់ដោយសមាសភាព ផសស ក្នុងនេះវិស័យឧស្សាហកម្មធ្លាក់អត្រាកំណើនរហូតដល់ -៩,៥% ហើយវិស័យសេវាកម្មមានដំណើរការអន់ខ្សោយ។ ប៉ុន្តែ សេដ្ឋកិច្ចចាប់ផ្ដើមបង្ហាញសញ្ញាងើបឡើងវិញនៅឆ្នាំ២០១០ ជាមួយនឹងកំណើន ៥,៩% ដោយសារសន្ទុះងើបឡើងវិញ លឿនជាងការរំពឹងទុកខាងវិស័យកាត់ដេរ ហើយការបើកផ្ដល់ FDI ក្នុងត្រីមាសទី៤ ឆ្នាំ២០១០ មានជិតស្មើនឹងទំហំក្នុងត្រីមាសទី២ ឆ្នាំ២០០៨ ដែលប្រការនេះឆ្លុះបញ្ចាំងពី ការងើបឡើងវិញយ៉ាងខ្លាំងក្នុងវិស័យរូបវន្ត (real sector)។

ដើម្បីទប់ទល់អតិផរណា ពង្រឹងសន្តិសុខស្បៀង ដែលជាបញ្ហាបន្តពីឆ្នាំ២០០៨ មានវិធានការបញ្ចូលប្រាក់ ១៨ លានដុល្លារទៅក្នុងធនាគារអភិវឌ្ឍន៍ជនបទ ដើម្បីបន្តលើកកម្ពស់សន្តិសុខស្បៀង។ ការធ្លាក់ចុះសេដ្ឋកិច្ចបានបង្កការបាត់បង់ការងារ និងការកាត់បន្ថយការងារ នៅក្នុងវិស័យប៉ះទង្គិចដោយវិបត្តិ ដូចជាកាត់ដេរ សំណង់ និងទេសចរណ៍។ ដោយពិនិត្យឃើញបញ្ហានេះ រដ្ឋាភិបាលបានចំណាយ ៦,៥ លានដុល្លារ សម្រាប់មូលនិធិបណ្ដុះបណ្ដាលពិសេស និង

១លានដុល្លារ សម្រាប់ការបង្កើតមុខរបរដោយខ្លួនឯង ព្រមទាំងជួយរួមចំណែកបង់ប្រាក់ បុព្វលាភហានិភ័យការងារ (occupational risk premium payment) ដើម្បីកាត់បន្ថយបន្ទុករបស់ក្រុមហ៊ុនកាត់ដេរ។ ដើម្បីជម្រុញកំណើនឡើងវិញតាមរយៈឥណទានទៅវិស័យឯកជន កម្រិតឥណទានលើវិស័យអចលនទ្រព្យត្រូវបានលើកលែង និងអត្រាកាតព្វកិច្ចទុនបម្រុង ត្រូវបានបន្ថយពី ១៦% មកត្រឹម ១២% ដើម្បីបង្កើនលំហូរឥណទាន។

នៅពេលការធ្លាក់ចុះសេដ្ឋកិច្ចសាកល កំពុងវិវត្តទៅមុខ ចំណុចផ្តោតសំខាន់គឺ ការអនុម័តវិធានការពង្រីកសារពើពន្ធ (fiscal expansion) ដើម្បីជម្រុញសកម្មភាពសេដ្ឋកិច្ច។ ខុសប្លែកពីឆមាសទី២ ឆ្នាំ២០០៨ ដែលកាលនោះ ការពង្រីកសារពើពន្ធមានទម្រង់ជាការលើកលែងពន្ធ វិធានការហិរញ្ញវត្ថុនៅឆ្នាំ២០០៩ មានទម្រង់ជាការបង្កើនចំណាយសាធារណៈ ដែលរួមមាន ចំណាយចរន្តកើនប្រហែល ២១៩លានដុល្លារ (២៧%) និងចំណាយមូលធនកើនប្រហែល ១៥៤លានដុល្លារ (៣១%)។ ដោយឃើញមានសញ្ញានៃការងើបសេដ្ឋកិច្ចឡើងវិញក្នុងឆ្នាំ២០១០ រដ្ឋាភិបាលក៏ចាប់ផ្តើមបន្ថយការពង្រីកសារពើពន្ធ ដែលនាំឲ្យមានកំណើនចំណាយចរន្តមកត្រឹម ១៥៩លានដុល្លារ (១៥%) និងកំណើនចំណាយមូលធន ៨៦លានដុល្លារ (១៣%) (ច្បាប់ថវិកាប្រចាំឆ្នាំ)។

ការពង្រីកសារពើពន្ធមិនគ្រប់គ្រាន់ ដើម្បីទប់ទល់នឹងវិបត្តិសេដ្ឋកិច្ចដ៏ធំធេងធ្ងរមិនធ្លាប់ជួប និងឥទ្ធិពលផ្សេងៗរបស់វាទេ គឺគ្រាន់តែអាចជួយជម្រុញតម្រូវការក្នុងស្រុកបានខ្លះ (SNEC 2011)។ ម្យ៉ាងទៀត ចំណូលរបស់រដ្ឋាភិបាលកើនតិចតួចណាស់ មិនទាន់គ្នានឹងកំណើនចំណាយប្រើប្រាស់របស់រដ្ឋាភិបាលទេ។ មានមូលហេតុជាច្រើនដែលអាចពន្យល់បាន។ កញ្ចប់បង្កើនចំណាយសាធារណៈ ដ៏តូចត្រឹមប្រហែល ៤,៥% នៃ ផសស ក្នុងឆ្នាំ២០០៩ និង ២,៨% នៃ ផសស ក្នុងឆ្នាំ២០១០ វាមិនគ្រប់គ្រាន់ទេ ដើម្បីបង្កើនសកម្មភាពសេដ្ឋកិច្ច (Jalilian and Reyes 2010)។ ប្រព័ន្ធសុវត្ថិភាពសង្គមនៅអន់ខ្សោយ ការបាត់បង់ការងារយ៉ាងច្រើន និងភាពមិនប្រាកដប្រជានៃប្រាក់ចំណូល បានបង្កើននិន្នាការសន្សំ (prospensity to save) ដែលបានរាំងស្ទះដល់ផលមេគុណ (multiplier effect) នៃចំណាយសាធារណៈ។ កំណើនចំណាយសាធារណៈ បានហូរចេញទៅក្រៅតាមការទូទាត់ថ្លៃទំនិញនាំចូល ដោយសារមូលដ្ឋានផលិតកម្មក្នុងស្រុកនៅអន់ខ្សោយ។ ម្យ៉ាងទៀត ប្រព័ន្ធស្ថាប័នគ្រប់គ្រងថវិកាអន់ខ្សោយ ធ្វើឲ្យចំណាយមួយភាគតូច ឆាកចេញពីគោលដៅអនុវត្តដែលចង់បាន។ កត្តាទាំងនេះបានគួបផ្សំគ្នាបង្កជាក្តីបារម្ភ អំពីប្រសិទ្ធភាពនៃយុទ្ធសាស្ត្រ និងសមត្ថភាពរបស់រដ្ឋាភិបាល ក្នុងការអនុវត្តកញ្ចប់វិធានការសង្គ្រោះ ក្នុងបរិការណ៍ដែលតួនាទីនៃវិធានការជម្រុញសេដ្ឋកិច្ច គឺនៅមានកម្រិត (Jalilian and Reyes 2010)។

សរុបមក រដ្ឋាភិបាលបានចាត់វិធានការល្អ និងភ្លាមៗគួរឲ្យកោតសរសើរ ដើម្បីលើកកម្ពស់សន្តិសុខស្បៀង និងរក្សាផលិតភាពនៅចំពោះមុខព្យុះវិបត្តិហិរញ្ញវត្ថុសាកលកន្លងមក។ ជាងនេះទៅទៀត ការអនុវត្តវិធានការពង្រីកសារពើពន្ធ ជាការចាំបាច់ និងទាន់ពេល ដើម្បីទប់ស្កាត់កំណើនអវិជ្ជមាន និងការបាត់បង់ការងារ។ ហើយទោះបីប្រសិទ្ធភាពមានកម្រិតក្តី ក៏គោលនយោបាយរូបិយវត្ថុ មានការសម្របសម្រួលយ៉ាងល្អ និងរលូនគ្នាជាមួយនឹងគោលនយោបាយសារពើពន្ធ។

## ដំណើរការក្រោយពីវិបត្តិសេដ្ឋកិច្ច

វិបត្តិបានបង្ហាញពី ប្រសិទ្ធភាពមានកម្រិតនៃគោលនយោបាយសារពើពន្ធ និងរូបិយវត្ថុ ក្នុងការទប់ទល់នឹងវិបត្តិមានប្រភពពីខាងក្រៅ។ ទោះយ៉ាងនេះក្តី យុទ្ធសាស្ត្រជម្រុញកំណើនផ្អែកលើការនាំចេញ និងនាំមុខដោយវិស័យឯកជន ដែលកម្ពុជាកំពុងអនុវត្តសព្វថ្ងៃ នៅតែមានលក្ខណៈល្អត្រឹមត្រូវជានិច្ច។

វិធានការ គោលនយោបាយម៉ាក្រូសេដ្ឋកិច្ចទាំងពីរ ត្រូវការការពង្រឹងបន្ថែម។ ការរឹតបន្តឹងសារពើពន្ធ នឹងបំពេញប្រាក់បញ្ញើរបស់រដ្ឋាភិបាលឡើងវិញ។ ទន្ទឹមនឹងនេះ ស្ថាប័នគ្រប់គ្រងថវិកាកាន់តែរឹងមាំ ដែលជាលទ្ធផលចង់បាននៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នឹងជួយកែលំអការធ្វើរដ្ឋបាលចំណូល និងប្រសិទ្ធភាពចំណាយ។ គោលនយោបាយរូបិយវត្ថុនឹងកាន់តែមានស្វ័យភាព និងមានជម្រើសច្រើនឡើង តាមរយៈការធ្វើបដិដុល្លារូបនីយកម្មជាបណ្តើរៗ និងការបង្កើតទីផ្សាររូបិយវត្ថុ។

គោលនយោបាយតាមវិស័យ នឹងបង្កើនប្រសិទ្ធភាព និងភាពបំពេញឲ្យគ្នានៃឧបករណ៍ម៉ាក្រូសេដ្ឋកិច្ចនានា។ ការផ្សព្វផ្សាយឯកសារគោលនយោបាយស្តីពី ការជម្រុញផលិតកម្មស្រូវ និងការនាំចេញអង្ករ និងយុទ្ធសាស្ត្រជាតិគាំពារសង្គមទើបអនុម័តថ្មី សុទ្ធសឹងជាសមិទ្ធផលដ៏សំខាន់ៗថែមទៀត។

☞ អគារលេខ ៥៦ ផ្លូវ ៣១៥ ទួលគោក
✉ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
☎ (៨៥៥-២៣) ៨៨១ ៣៨៤/៨៨១ ៧០១/៨៨១ ៩១៦/៨៨៣ ៦០៣
🖷 (៨៥៥-២៣) ៨៨០ ៧៣៤
អ៊ីមែល៖ cdri@cdri.org.kh
គេហទំព័រ៖ http://www.cdri.org.kh

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ នៅឆ្នាំ២០១២-២០២០ និងកញ្ចប់គោលនយោបាយ ដើម្បីជម្រុញការអភិវឌ្ឍឧស្សាហកម្មនាពេលខាងមុខ នឹងផ្តល់ជាមូលដ្ឋានគ្រប់ជ្រុងជ្រោយ សម្រាប់អន្តរាគមន៍ខាងម៉ាក្រូសេដ្ឋកិច្ចកាន់តែប្រសើរនាពេលអនាគត។

## ឯកសារយោង

Chan Sophal (2008), *Impact of High Food Prices in Cambodia*, CDRI Policy Brief No. 2 (Phnom Penh: CDRI)

Chea Ravin & Ung Luyna (2011), "The Effectiveness of Macroeconomic Policies in Cambodia: An Empirical Study", Draft Report

Ginting, Edimon & Kelly Bird (2009), *Explaining Inflation in Cambodia*, Asia Development Bank, paper presented at Cambodian Economic Forum. 5 February 2009 Working Paper

Hang Chuon Naron (2008), "Three Essays on Macroeconomic Management of Cambodia", (Phnom Penh: Ministry of Economy and Finance)

Jalilian, Hossein, Chan Sophal, Glenda Reyes, Saing Chan Hang, Phann Dalis & Pon Dorina (2009), "Global Financial Crisis Discussion Series - Paper 4: Cambodia" (London: ODI)

Jalilian, Hossein & Glenda Reyes (2010), "Global Financial Crisis Discussion Series - Paper 14: Cambodia Phase 2" (London: ODI)

Plata, P.V. & A.G. Herrero (2008), "To Dollarize or De-dollarize: Consequences for Monetary Policy", Discussion Paper (Berlin: German Institute for Economic Research)

Supreme National Economic Council (2011), *Enhancing Fiscal Reform and the Counter-Cyclical Aspects of Fiscal Policy in Cambodia*, Draft Working Paper (Phnom Penh: RGC)